ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៣៨៥៨ សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជំនាញបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា និងឌីជីថល ជាលើកទី២ ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

យោងលិខិតលេខ៣៧៤៨ សជណ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៦ ស្តីពីការប្រឡងប្រជែងជ្រើសរើសបេក្ខជនជំនាញបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា និងឌីជីថល ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ គណៈកម្មការរៀបចំការប្រឡងមានកិត្តិយសសូមជម្រាបជូនសាធារណជន ជាលើកទី២ ជ្រាបថា ក្រសួងមហាផ្ទៃជ្រើសរើសបេក្ខជនជំនាញបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា និងឌីជីថល ឱ្យបម្រើការងារនៅអង្គភាពនគរបាលចំណុះក្រសួងមហាផ្ទៃ ដូចខាងក្រោម៖

១- អគ្គស្នងការដ្ឋាននគរបាលជាតិ	ចំនួន	៤៨នាក់	ស្រី ១៤នាក់
២- បណ្ឌិត្យសភានគរបាលកម្ពុជា	ចំនួន	១០នាក់	ស្រី ៣នាក់
៣- អគ្គនាយកដ្ឋានធនធានមនុស្ស	ចំនួន	៧នាក់	ស្រី ២នាក់
៤- អគ្គលេខាធិការដ្ឋាន	ចំនួន	៥នាក់	ស្រី ១នាក់
៥- អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ	ចំនួន	៥នាក់	ស្រី ១នាក់
៦- អគ្គនាយកដ្ឋានអន្តោប្រវេសន៍	ចំនួន	៥នាក់	ស្រី ១នាក់
៧- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម	ចំនួន	៥នាក់	ស្រី ១នាក់
៨- អគ្គាធិការដ្ឋាន	ចំនួន	៥នាក់	ស្រី ១នាក់
៩- អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង	ចំនួន	៥នាក់	ស្រី ១នាក់
១០- ក្រុមប្រឹក្សានីតិកម្ម	ចំនួន	៥នាក់	ស្រី ១នាក់

ក- លក្ខខណ្ឌនៃការជ្រើសរើស

- បេក្ខជនទាំងពីរភេទ មានសញ្ជាតិខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ច្បាស់លាស់
- មានជីវប្រវត្តិច្បាស់លាស់ មានកិរិយាមារយាទល្អ និងពុំធ្លាប់មានពិរុទ្ធភាពកន្លងមក
- មានកាយសម្បទាគ្រប់គ្រាន់ និងមានសុខភាពល្អ (ឆ្លងកាត់ការត្រួតពិនិត្យភ្នែក ត្រចៀក ច្រមុះ មាត់ បេះដូង ថ្លើម សួត ក្រុមឈាម តេស្តរកសារធាតុញៀន និងគ្មានជំងឺប្រចាំកាយ)
- មិនមានស្លាកស្នាមរបួស ឬស្លាកស្នាមសាក់
- បុរសមានកម្ពស់ ១,៧០ម៉ែត្រឡើង នារីមានកម្ពស់ ១,៦៥ម៉ែត្រឡើង និងមានទម្ងន់សមាមាត្រនឹងកម្ពស់

- មានសញ្ញាបត្របរិញ្ញាបត្រទាក់ទងនឹងជំនាញបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា និងឌីជីថល និងមានអាយុយ៉ាងច្រើនត្រឹម ៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានអាយុយ៉ាងច្រើនត្រឹម ៣៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង។

ខ- កាលបរិច្ឆេទនិងទីកន្លែងផ្តល់ពាក្យនិងទទួលពាក្យ

- ផ្តល់ពាក្យ ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៦
- ទទួលពាក្យ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៦
- កន្លែងផ្តល់និងទទួលពាក្យ នៅអគារស្ថានីយវិទ្យុនិងទូរទស្សន៍មហាផ្ទៃ នៃទីស្តីការក្រសួងមហាផ្ទៃ។

គ- កាលបរិច្ឆេទនិងមណ្ឌលប្រឡង

កាលបរិច្ឆេទនិងមណ្ឌលប្រឡងនឹងជូនដំណឹងនៅពេលក្រោយ។

ឃ- ការចុះឈ្មោះតាមប្រព័ន្ធបច្ចេកវិទ្យា

បេក្ខជនម្នាក់ៗតម្រូវឱ្យចុះឈ្មោះតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីស្នើសុំសិទ្ធិប្រឡងប្រជែង ដោយត្រូវបំពេញព័ត៌មានបឋមតាមតំណភ្ជាប់ (https://gdhr.interior.gov.kh/appform/request?recruit=9f3bc005) ឬស្កែន QR CODE រួចបោះពុម្ព(Print)បង្កាន់ដៃស្នើសុំពាក្យ ទុកបង្ហាញអនុគណៈកម្មការផ្តល់ពាក្យនិងទទួលពាក្យបេក្ខជន នៅទីកន្លែងផ្តល់ពាក្យសុំចូលបម្រើការងារ។

ង- ឯកសារដែលត្រូវភ្ជាប់មកជាមួយ

នៅពេលបេក្ខជនម្នាក់ៗមកទទួលពាក្យសុំចូលបម្រើការងារ ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- បង្កាន់ដៃស្នើសុំពាក្យ ដែលបានស្នើសុំតាមប្រព័ន្ធបច្ចេកវិទ្យា.....១ច្បាប់
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ច្បាប់ដើមនិងថតចម្លង).....១ច្បាប់
- សញ្ញាបត្របរិញ្ញាបត្រ (ច្បាប់ដើមនិងថតចម្លង).....១ច្បាប់
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (ច្បាប់ដើមនិងថតចម្លង).....១ច្បាប់
- សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត (ច្បាប់ដើមនិងថតចម្លង).....១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ដើមនិងថតចម្លង).....១ច្បាប់
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ (ច្បាប់ដើមនិងថតចម្លង).....១ច្បាប់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៣រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០២៦

អ្នកលេខាធិការ
និងជាប្រធានគណៈកម្មការរៀបចំការប្រឡង

សន្តិបណ្ឌិត.ចាន់ ភ័ណ

សូមបេក្ខជន
ទាញយកបង្កាន់ដៃស្នើសុំពាក្យ
ដោយស្កែន QR Code

ឬតាមតំណភ្ជាប់
https://gdhr.interior.gov.kh/appform/request?recruit=9f3bc005